ទីក្រុង LAKEWOOD

សូមកត់សម្គាល់ថា មិនមានបេក្ខជនណាច្រើនជាងមុខតំណែងដែលត្រូវបោះឆ្នោតជ្រើសរើសនៅក្នុងមណ្ឌលក្រុមប្រឹក្សាទី 1 និងទី 5

សូមកត់សម្គាល់ អនុលោតាមក្រមបោះឆ្នោត មាត្រាទី § 10229 ដែលគ្រប់គ្រងការបោះឆ្នោតសាលាក្រុងទូទៅនៅក្នុងទីក្រុង Lakewood ដែលនឹងប្រារព្ធធ្វើឡើងនៅថ្ងៃអង្គារ ទី 2 ខែមិថុនា ឆ្នាំ 2026៖

គិតត្រឹមការបិទបញ្ចប់នៃរយៈពេលតែងតាំងនៅថ្ងៃទី 6 ខែមីនា ឆ្នាំ 2026 វេលាម៉ោង 5:00 ល្ងាច បេក្ខជនម្នាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានសិទ្ធិទទួលបានមុខតំណែងជាប់ឆ្នោតនីមួយៗដូចខាងក្រោម៖

មណ្ឌលក្រុមប្រឹក្សាទី 1៖ Todd Rogers

មណ្ឌលក្រុមប្រឹក្សាទី 5៖ Cassandra Chase

ក្រមបោះឆ្នោត មាត្រាទី § 10229 ចែងពី ការអនុញ្ញាត ឱ្យក្រុមប្រឹក្សាក្រុងចាត់វិធានការមួយក្នុងចំណោមវិធានការដូចខាងក្រោម នៅពេលដែលមិនមានបេក្ខជនច្រើនជាងមុខតំណែងដែលត្រូវបោះឆ្នោតជ្រើសរើស៖

1. តែងតាំងមនុស្សម្នាក់ក្នុងចំណោមបុគ្គលដែលត្រូវបានតែងតាំងនៅក្នុងមុខតំណែងទំនេរនីមួយៗ។
2. តែងតាំងអ្នកមានសិទ្ធិបោះឆ្នោតណាមួយឱ្យចូលកាន់តំណែង ប្រសិនបើគ្មានជនណាម្នាក់ត្រូវបានតែងតាំង។
3. រៀបចំការបោះឆ្នោត ប្រសិនបើគ្មានជនណាម្នាក់ ឬមានតែបុគ្គលម្នាក់ប៉ុណ្ណោះដែលត្រូវបានតែងតាំង។

នៅក្នុងកិច្ចប្រជុំពិសេសមួយរបស់ក្រុមប្រឹក្សាក្រុង ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី 17 ខែមីនា ឆ្នាំ 2026 វេលាម៉ោង 2:00 រសៀល ក្រុមប្រឹក្សាក្រុងនឹងពិចារណាថាតើត្រូវធ្វើការតែងតាំង ឬបង្គាប់បញ្ជាឲ្យរៀបចំការបោះឆ្នោតដែរឬទេ។ បុគ្គលដែលត្រូវបានតែងតាំង ប្រសិនបើមាន នឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងចូលកាន់តំណែង និងបម្រើការងារយ៉ាងពិតប្រាកដដូចដែលត្រូវបានជ្រើសតាំងនៅក្នុងការបោះឆ្នោតសាលាក្រុងសម្រាប់តំណែងនោះ។

ប្រសិនបើ នៅត្រឹមថ្ងៃទី 75 មុនការបោះឆ្នោតសាលាក្រុង (ថ្ងៃទី 19 ខែមីនា ឆ្នាំ 2026) គ្មានបុគ្គលណាម្នាក់ត្រូវបានតែងតាំងឲ្យទៅកាន់តំណែងនីមួយៗទាំងនេះ អនុលោមតាមចំណុច (1) ឬ (2) ខាងលើទេ នោះការបោះឆ្នោតសម្រាប់មណ្ឌលក្រុមប្រឹក្សាទី 1 និងទី 5 ត្រូវតែប្រារព្ធធ្វើឡើង រួមជាមួយនឹងមុខតំណែងដែលជ្រើសរើសតាមរយៈការបោះឆ្នោតផ្សេងទៀតទាំងអស់នៅលើសន្លឹកឆ្នោត។ ប្រសិនបើការតែងតាំងត្រូវបានធ្វើឡើងឲ្យកាន់តំណែងទាំងនេះ ការបោះឆ្នោតសម្រាប់មណ្ឌលក្រុមប្រឹក្សាទី 1 និងទី 5 នឹងត្រូវបានលុបចោល ប៉ុន្តែនឹងត្រូវប្រារព្ធធ្វើឡើងសម្រាប់មុខតំណែងដែលជ្រើសរើសតាមរយៈការបោះឆ្នោតផ្សេងទៀតទាំងអស់នៅលើសន្លឹកឆ្នោត។

ប្រសិនបើក្រុមប្រឹក្សាក្រុងធ្វើការតែងតាំងអនុលោមតាមក្រមបោះឆ្នោត មាត្រាទី § 10229 នោះស្មៀនសាលាក្រុងមិនអាចទទួលយកការដាក់សេចក្តីថ្លែងការណ៍ណាមួយរបស់បេក្ខជនខាងក្រៅដែលមិនមានឈ្មោះនៅលើសន្លឹកឆ្នោតត្រូវបានដាក់ជូនបន្ទាប់ពីបានធ្វើការតែងតាំងរួចហើយនោះទេ។

Isabelle Schultz ជំនួយការស្មៀនសាលាក្រុង
ចុះកាលបរិច្ឆេទ៖ ថ្ងៃទី 11 ខែមីនា ឆ្នាំ 2026

5050 N. Clark Avenue • Lakewood, California 90712 • (562) 866-9771 • www.lakewoodca.gov